**ឯកសារសង្ខេប**

គណៈកម្មការទី៨ ព្រឹទ្ធសភា ទទួលបន្ទុកសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

# "អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា"

អ្នកស្រាវជ្រាវ៖ **គឹម កែវធីតា**

ខែមីនា ឆ្នាំ២០១៤

**វិទ្យាស្ថានសភាកម្ពុជា**

# មាតិកា

សេចក្តីផ្តើម....................................................................................................1

១-តើអ្វីទៅជាអំពើហិង្សាក្នុងគ្រួសារ?....................................................................1

២-តើបច្ចុប្បន្នអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាមានស្ថានភាពយ៉ាងដូចម្តេចខ្លះ?.....................2

៣- តើកត្តាអ្វីខ្លះដែលបណ្តាលឲ្យមានអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា?...............................2

៤. តើមានផលប៉ះពាល់អ្វីខ្លះនៃអំពើហិង្សាក្នុងគ្រួសារទៅលើជនរងគ្រោះនិងអ្នកដែលក្នុង គ្រួសារ និង សហគមន៍ទាំងមូល?..........................................................................................4

៥. តើមានច្បាប់របស់ប្រទេសកម្ពុជា និងអនុសញ្ញាអន្តជាតិពាក់ព័ន្ធអ្វីខ្លះ ប្រឆាំងនឹងអំពើហិង្សាក្នុង គ្រួសារ?...........................................................................................................5

៦. តើប្រទេសកម្ពុជាបច្ចុប្បន្ន មានគោលនយោបាយអ្វីខ្លះ ដើម្បីឆ្លើយតបការទប់ស្កាត់អំពើហិង្សាក្នុង គ្រួសារ?...........................................................................................................6

៧. សេចក្តីសន្និដ្ឋាន ...............................................................................................7

គន្ថនិទេស .......................................................................................................8

# សេចក្តីផ្តើម

ឯកសារសង្ខេបនេះផ្តោតលើអំពើហិង្សាក្នុងគ្រួសារនៅប្រទេសកម្ពុជា។ជារួមឯកសារនេះបង្ហាញថាអំពើហិង្សាក្នុងគ្រួសារនៅតែជាបញ្ហាដ៏ធ្ងន់ធ្ងរមួយនៅកម្ពុជា ដោយសារតែស្រ្តីមានអំណាចទាបជាងបុរស ការប្រើប្រាស់គ្រឿងស្រវឹង និងការយល់ដឹងពីតួនាទីយេនឌ័រនៅមិនទាន់សូវយកចិត្តទុកដាក់នៅឡើយ។ កន្លងមក ទោះបីជាប្រទេសកម្ពុជាមានច្បាប់សំខាន់ៗជាច្រើន ដែលបានដោះស្រាយលើបញ្ហាដែលទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ និងបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធមួយចំនួនក៏ដោយ ក៏បញ្ហានៅតែបន្តកើតមាន ក្នុងការផ្តល់ការគាំទ្រយ៉ាងមានប្រសិទ្ធភាពដល់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ។ ទោះជាយ៉ាងណា ក៏ដោយរាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវគោលនយោបាយមួយចំនួនដើម្បីកែប្រែស្ថានភាពនេះនៅឆ្នាំខាងមុខនេះ។

ឯកសារនេះនឹងបកស្រាយនូវសំនួរដូចតទៅ៖ តើអ្វីទៅជាអំពើហិង្សាក្នុងគ្រួសារ(១)?តើបច្ចុប្បន្នអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាមានស្ថានភាពយ៉ាងដូចម្តេចដែរ(២)? តើកត្តាអ្វីខ្លះដែលបណ្តាលឲ្យមានអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា(៣)?តើមានផលប៉ះពាល់អ្វីខ្លះពីអំពើហិង្សាក្នុងគ្រួសារនៅលើជនរងគ្រោះ អ្នកដែលនៅក្នុងគ្រួសារ និងសហគមទាំងមូល(៤)? តើមានច្បាប់របស់ប្រទេសកម្ពុជា និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធអ្វីខ្លះប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ(៥)?តើបច្ចុប្បន្នមានគោលនយោបាយអ្វីខ្លះប្រឆាំងទៅនឹងអំពើហិង្សាក្នុងគ្រួសារ(៦)?

## ១-តើអ្វីទៅជាអំពើហិង្សាក្នុងគ្រួសារ ?

អំពើហិង្សាក្នុងគ្រួសារគឺជាជម្លោះរំលោភបំពានដែលកើតឡើងរវាងមនុស្សពីរនាក់ដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ដូចជាប្តី-ប្រពន្ធ ឪពុកឬម្តាយ និងកូនដែលនៅក្នុងបន្ទុក ឬបុរសស្រ្តី ឬក៏មនុស្សផ្សេងទៀតដែលរស់នៅក្នុងផ្ទះតែមួយ[1]។

យោងទៅតាមច្បាប់របស់ប្រទេសកម្ពុជាស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះអំពើហិង្សាក្នុងគ្រួសារអាចធ្វើបានតាមរយៈរាងកាយ ពាក្យសំដីផ្លូវចិត្តអារម្មណ៍ ផ្លូវភេទ និងសេដ្ឋកិច្ច។ច្បាប់នេះបានកំណត់អំពើហិង្សាក្នុងគ្រួសារមានបួនប្រភេទ[2]៖

[1] "Understanding Family Violence in Cambodia" ,Peace Resources, Accessed on March 14,2014 from http://pbresources.blogspot.com/2009/06/part-1-basic-understandings-of-violence.html

[2] Law on the Prevention of Domestic Violence and the Protection of Victims, (Article 3),promulgatedNS/RPM/1005/035, dated 24th October 2005

- **អំពើហិង្សាលើរាងកាយៈ** អំពើហិង្សាដែលកើតឡើងនៅពេលដែលមនុស្សម្នាក់ធ្វើឲ្យគេឈឺចាប់ឬព្យាយាមធ្វើឲ្យដៃគូឈឺចាប់តាមរយៈកម្លាំងកាយ[3]។
- **អំពើហិង្សាលើផ្លូវចិត្តៈ** អំពើហិង្សាដែលបានបណ្តាលឲ្យជនរងគ្រោះទទួលរងការឈឺចាប់ផ្លូវចិត្តឬមានជម្ងឺផ្លូវចិត្ត[4]។
- **អំពើហិង្សាលើផ្លូវភេទៈ** អំពើហិង្សាដែលបណ្តាលឲ្យមនុស្សម្នាក់ទទួលរងកាបៀតបៀនផ្លូវភេទ ឬទង្វើផ្លូវភេទដែលមិនមានការឯកភាព[5] និង
- **អំពើហិង្សាលើផ្នែកសេដ្ឋកិច្ចៈ** អំពើហិង្សាដែលបានធ្វើឲ្យស្ត្រីម្នាក់មានការព្រួយបារម្ភពីការគាំទ្រផ្នែកហិរញ្ញវត្ថុ។ជាធម្មតាបណ្តាលមកពីស្ត្រីក្លាយជាអ្នកពឹងផ្អែកលើសេដ្ឋកិច្ចរបស់បុរស[6]។

## ២-តើបច្ចុប្បន្នអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាមានស្ថានភាពយ៉ាងដូចម្តេចខ្លះ?

របាយការណ៍របស់អង្គការសហប្រជាជាតិមួយឆ្នាំ២០១៣បានបង្ហាញថា មាន២២%នៃស្ត្រីកម្ពុជាធ្លាប់ទទួលរងនូវអំពើហិង្សាលើផ្លូវកាយ និងផ្លូវភេទ ខណៈពេលដែល ៦,៤% កំពុងឆ្លងកាត់អំពើហិង្សានៅពេលបច្ចុប្បន្ន។ ដូចគ្នានេះផងដែរ បុរសមានអត្រា ១៦% រងគ្រោះនឹងអំពើហិង្សាក្នុងគ្រួសារ និង៣% កំពុងរងគ្រោះនឹងអំពើហិង្សាក្នុងគ្រួសារ[7]។ ទោះបីជាយ៉ាងណាក៏ដោយ ទាំងនេះមិនបានបញ្ចូលទម្រង់ផ្សេងៗទៀតនៅក្នុងអត្រាដែលបាន បង្ហាញខាងលើទេដូចជាអំពើហិង្សាផ្លូវចិត្តឬសេដ្ឋកិច្ចជាដើម ពីព្រោះមិនទាន់មានទិន្នន័យថ្មីៗ។

## ៣- តើកត្តាអ្វីខ្លះដែលបណ្តាលឲ្យមានអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា?

មូលហេតុដែលបណ្តាលឲ្យមានអំពើហិង្សាក្នុងគ្រួសារនៅក្នុងប្រទេសកម្ពុជាអាចនឹងកើតមានឡើងដោយសារតែកត្តាមួយចំនួនរួមមានជំនឿតាមបែបប្រពៃណី ការប្រើប្រាស់គ្រឿងស្រវឹង កម្រិតនៃការអប់រំទាប ភាពគ្មានការងារធ្វើការជួបប្រទះការលំបាកផ្នែកសេដ្ឋកិច្ចក្នុងសង្គម។[8]ការរួមចំណែកពីជំនឿប្រពៃណី គ្រឿងស្រវឹង និងភាពអត់ការងារធ្វើបណ្តាលឲ្យមានអំពើហិង្សាក្នុងគ្រួសារនឹងត្រូវបានបង្ហាញដូចខាងក្រោម៖

---

[3]Ibid,(Article5)
[4] Ibid,(Article6)
[5]UNDP Cambodia and VBNK in collaboration with the Ministry of Justice and the Ministry of Interior,2010"Talking about domestic violence in Cambodia",p21
[6] Ibid
[7]Fulu, E., Warner, X. Miedema, S. Jewkes, R. Roselli, T. and Land, J. (2013).*Why Do Some Men Use Violence Against Women and How Can We Prevent It? Quantitative Findings from the United Nations Multi-Country Study on Men and Violence in Asia and the Pacific*. Bangkok: UNDP, UNFPA, UN Women and UNV.
[8]Ibid,p27

**ក.កត្តាជំនឿប្រពៃណី**:កម្ពុជាជាសង្គមមួយដែលមានឋានានុក្រមយូរយារណាស់មកហើយ និងមានវប្បធម៌ទំនៀមទំលាប់ដោយដាក់ក្តីសង្ឃឹមលើបុគ្គលដែលបានប្រព្រឹត្តសមរម្យទៅតាមតួនាទីរបស់ខ្លួនក្នុងសង្គម។[9] ឧទាហរណ៍ ស្ត្រី៨១% និងបុរស៧៥% មានជំនឿថាស្ត្រីគួរតែនៅផ្ទះថែរក្សាគ្រួសារ។[10]

ទាំងនេះជាផ្នែកមួយនៃលទ្ធិតាមបែបជំនឿប្រពៃណីដែលនៅតែចាក់ឫសយ៉ាងជ្រៅនៅក្នុងគ្រួសារជាច្រើននៅកម្ពុជាដែលបង្ហាញពីអំណាចដ៏រឹងមាំ និងតួនាទីរបស់បុរសនៅក្នុងគ្រួសាររបស់ពួកគេ ។ ហេតុដូច្នេះហើយ បុរសភាគច្រើនមានជឿថាស្ត្រីគួរតែតែស្តាប់បង្គាប់ពួកគេ ហើយបែកចែកកាតព្វកិច្ចក្នុងគ្រួសារតាមវិធីជាក់លាក់មួយ។ លើសពីនេះទៀត នៅប្រទេសកម្ពុជាអំពើហិង្សាក្នុងគ្រួសារមិនមែនជារឿងចម្លែក សម្រាប់គ្រួសារមួយចំនួនដែលមានយល់ថាបុរសពិតប្រាកដគួរតែកោងកាច និងស្ត្រីពិតប្រាកដគួរតែស្តាប់បង្គាប់។[11] កត្តានេះ បង្កើតបានមូលដ្ឋានទំនៀមទម្លាប់មួយ សម្រាប់ជម្លោះប្តី-ប្រពន្ធក្លាយជាអំពើហឹង្សា និងបណ្តាលឲ្យស្ត្រី និងកុមារនៅក្នុងប្រទេសកម្ពុជាក្លាយជាជនងាយរងគ្រោះពីអំពើហិង្សា និងការរំលោភបំពានទាំងនេះ។[12]

ផលប៉ះពាល់នៃកត្តាជំនឿប្រពៃណីទាំងនេះមានភាពច្បាស់លាស់នៅពេលដែលគេបានបង្ហាញថា ៣៥% ទៅ ៤៥% នៃអាជ្ញាធរមូលដ្ឋានយល់ថាប្តីមានសិទ្ធស្របច្បាប់ក្នុងការប្រើប្រាស់អំពើហិង្សាប្រសិនបើពួកគេមានអារម្មណ៍ថាភរិយាមិនបានគោរពប្រតិបត្តិ ឬឈ្លោះប្រកែកជាមួយពួកគេ។[13] ដោយផ្អែកលើការស្ទង់មតិ ឆ្នាំ២០០៩ មានបុរស៨៣% និងស្ត្រី៨១% នៅក្នុងប្រទេសកម្ពុជាមិនបានរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារដល់អាជ្ញាធរនៅពេលដែលមានអំពើហិង្សាកើតឡើងនោះទេ។[14]

**ខ. ការប្រើប្រាស់គ្រឿងស្រវឹង**: ការសេពគ្រឿងស្រវឹងកាត់បន្ថយការគ្រប់គ្រងលើខ្លួនឯង ដែលអាចបង្កើនឲ្យពួកគេបាត់បង់អារម្មណ៍ និងសំដែងឥរិយាបទបំផ្លិចបំផ្លាញ ឬក្លាយជាអំពើហឹង្សា។[15] តាមការស្រាវជ្រាវឆ្នាំ២០០៩ ដោយក្រសួងកិច្ចការនារីបានរកឃើញថាគ្រឿងស្រវឹងត្រូវបានជាប់ពាក់ព័ន្ធចាប់ពី៨២%ទៅ៩៦%នៃការរំលោភបំពានដោយពាក្យសំដីពី ៦ ទៅ ៩% បំផ្លាញរបស់របរ ៣% វាយដំ និង២%គម្រាមកំហែងភរិយាដោយប្រើប្រាស់កាំបិត យ៉ាងតិចកើតឡើងមួយម្តងក្នុងមួយសប្តាហ៍នៅពេលដែលពួកគេសេពគ្រឿងស្រវឹង។[16] ផ្អែកលើទិន្នន័យនេះ ការសេពគ្រឿងស្រវឹងជាកត្តារួមចំណែកដល់អំពើហិង្សាក្នុងគ្រួសារ។

[9]“Talking about domestic violence in Cambodia”,op.cit.,p27
“Report Finds Poor Implementation of Domestic Violence Law”. Cambodia daily.com. January 21,2014
[10]“Report Finds Poor Implementation of Domestic Violence Law”. Cambodia daily.com. January 21,2014
[11]Women and children in Cambodia are particularly vulnerable to violence and abuse, accessed on March 14, 2014. http://wopema.org/index.php?id=20
[12]Ibid. p74
[13]Ministry of Women's Affairs 2009, “ The Violence Against Women 2009 Follow Up Survey”,p.79
[14]Ibid.
[15]“Talking about domestic violence in Cambodia”,op.cit.,p21
[16]“Violence against women:2009Follow-up survey”,,op.cit.,p45

**គ.ភាពអត់ការងារធ្វើ:** យោងទៅតាមរបាយការណ៍របស់វិទ្យាស្ថានជាតិយុត្តិធម៌បានបង្ហាញថា៤,៧% នៃអំពើហិង្សា កើតឡើងនៅពេលដែលដៃគូបុរសស្ត្រីរបស់ពួកគេគ្មានការងារធ្វើ។ ប៉ុន្តែជាទូទៅ អំពើហិង្សាក្នុងគ្រួសារបានកើនឡើងរហូតដល់ ៧.៥% នៅពេលដែលបុរសនោះ ជួបប្រទះភាពអត់ការងារធ្វើមួយដង និងកើនឡើងរហូតដល់១២.៣% នៅពេលដែលបុរសនោះ ជួបប្រទះភាពអត់ការងារធ្វើរយៈពេលពីរទៅច្រើនដង[17]។

## ៤. តើមានផលប៉ះពាល់អ្វីខ្លះនៃអំពើហិង្សាក្នុងគ្រួសារនៅលើជនរងគ្រោះនិងអ្នកដែលក្នុងគ្រួសារ និងសហគមន៍ទាំងមូល?

អំពើហិង្សាក្នុងគ្រួសារមានផលប៉ះពាល់យ៉ាងខ្លាំង ទាំងផ្នែកសេដ្ឋកិច្ច ផ្លូវកាយ និងផ្លូវចិត្តទៅលើអ្នកណាដែលបានជួបប្រទះបញ្ហានេះ រួមទាំងគ្រួសារអ្នកមាន និងអ្នកក្រផងដែរ។[18] អំពើហិង្សាផ្នែករាងកាយអាចបណ្តាលឲ្យមានរបួសធ្ងន់ធ្ងរ ដែលតម្រូវឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រ ធ្វើឲ្យខូចខាតដល់ទ្រព្យសម្បត្តិឬធ្វើឲ្យបាត់បង់សមត្ថភាពធ្វើការ និងការរកប្រាក់ចំណូល។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបស្តីអំពីផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារទៅលើសេដ្ឋកិច្ច កុមារ សហគមន៍ និងសង្គម។

**ក. ការខាតបង់ចំណូល** :ស្ត្រីរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ តាមរបាយការណ៍បង្ហាញថា ជាមធ្យមបាត់បង់ចំណូលចំនួន ៤៦,០៩ដុល្លារអាមេរិក និងបុរសខាតបង់ចំនួន២៦,០២ដុល្លារអាមេរិកក្នុងមួយខែ។[19] ការខាតបង់នេះខ្ពស់ក្នុងចំណោមអ្នកដែលមានប្រាក់ចំណូលទាប ហើយកាន់តែមានការខាតបង់ធ្ងន់ធ្ងរសម្រាប់អ្នកដែលរស់នៅតាមជនបទ។[20]

**ខ. ផលប៉ះពាល់ទៅលើកុមារ** :កុមារប្រហែលជា៨០%ធ្លាប់បានឃើញឪពុកម្តាយវាយកូន។ ហើយពាក់កណ្តាលនៃកុមារទាំងនោះធ្លាប់ត្រូវបានឪពុកម្តាយរបស់ពួកគាត់វាយដំ[21]។ យោងទៅតាមរបាយការណ៍របស់សមាគមអាដហុក ក្នុងចំណោមជនរងគ្រោះពីអំពីហិង្សាក្នុងគ្រួសារចំនួន ១.១១៤នាក់ មាន៧២៦នាក់ជាកុមារដែលរស់នៅក្នុងគ្រួសារដែលមានអំពើហិង្សាក្នុងគ្រួសារធ្ងន់ធ្ងរ។ ជាមួយការប្រឈមនឹងអំពើហិង្សានេះអាចប៉ះពាល់យ៉ាងខ្លាំងទាំងផ្នែកផ្លូវកាយ ចិត្តនិងការអភិវឌ្ឍន៍ផ្នែកស្មារតីរបស់កុមារ និងរំខានដល់ការសិក្សារបស់ពួកគាត់[22]។ លើសពីនេះទៅទៀត កុមាររងគ្រោះឬអ្នកដែលបានឃើញអំពើហិង្សាក្នុងគ្រួសារអាចក្លាយជាអ្នកប្រព្រឹត្តអំពើហិង្សានៅ

---

[17]Ministry of women's affairs, "Explanatory Notes on the law on the prevention of domestic violence and the protection of the victims"(Cambodia: Ministry of women's affairs 2007),p. 18
[18]Ministry of women's affairs, "Violence against women:2009Follow-up survey", Final report 2009, (Cambodia: Ministry of women's affairs),p36
[19]Ibid p37
[20] "Violence against women", A baseline survey, Final Report Cambodia 2005,p36
[21] Talking about domestic violence,op.cit., p33
[22]UNDP Cambodia and VBNK in collaboration with the Ministry of Justice and the Ministry of Interior,2010"Talking about domestic violence in Cambodia",p34

ពេលអនាគត ។ កុមារទាំងនេះអាចរៀនតាមឪពុកម្ដាយរបស់ពួកគេដែលជម្លោះត្រូវបានដោះស្រាយ ដោយប្រើហិង្សា[23] ដែលនេះបង្កើតភាពមិនចេះចប់មិនចេះហើយនៃការរំលោភបំពាន។

**គ. ផលប៉ះពាល់ទៅសង្គម**:ខណៈដែលអំពើហិង្សាកើតឡើងច្រើន បង្ហាញយ៉ាងច្បាស់អំពីការរំខានដល់ភាពសុខសាន្តរបស់សង្គម បញ្ហានេះក៏បង្កឲ្យមានការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារការថយចុះកម្លាំងការងារ និងការទទួលបានការអប់រំទាប ដែលទាំងនេះធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ការអភិវឌ្ឍន៍សង្គម[24]។

## ៥. តើមានច្បាប់របស់ប្រទេសកម្ពុជា និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធអ្វីខ្លះ ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ?

បញ្ញត្តិទាំងឡាយរបស់ប្រទេសកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តិអន្តរជាតិប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារដែលកម្ពុជាជាហត្ថលេខីមានដូចខាងក្រោម៖

**ក. រដ្ឋធម្មនុញ្ញ (២០១០)** មានមាត្រាដែលទាក់ទងនឹងអំពើហិង្សាដូចខាងក្រោម៖ សិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រីចំពោះមុខច្បាប់ (មាត្រា៣១[25]) សិទ្ធិរស់រានមានជីវិត សេរីភាពនិងសុវត្ថិភាពផ្ទាល់ខ្លួន (មាត្រា៣២[26]) ច្បាប់ត្រូវតែការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ (មាត្រា៣៨[27]) ហាមមិនឲ្យមានការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រី (មាត្រា៤៥[28]) ការពារសិទ្ធិរបស់កុមារ (មាត្រា៤៨[29]) និងសុខភាពរបស់ប្រជាពលរដ្ឋត្រូវបានធានា (មាត្រា៧២[30])

**ខ. ក្រមព្រហ្មទណ្ឌ(២០០៩)** :បានទទួលស្គាល់ចំណុចជាច្រើននៃអំពើហិង្សាក្នុងគ្រួសារថាជាបទល្មើសព្រហ្មទណ្ឌ(មាត្រា២១៧-២៣០)[31]។

**គ. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ(២០០៥):** ច្បាប់នេះដោះស្រាយជាពិសេសលើបញ្ហាអំពើហិង្សាក្នុងគ្រួសារ ។ ច្បាប់នេះមានគោលបំណងការពារស្វាមី-ភរិយា កូននៅក្នុងបន្ទុក និងសមាជិកផ្សេងទៀតដែលរស់នៅក្នុងដំបូលផ្ទះតែមួយ តាមរយៈការទទួលស្គាល់

---

[23]Ibid. p34
[24]Ibid.p33
[25] Ibid .p10
[26] Ibid.p11
[27] Ibid.p13
[28] Ibid.p15
[29]Ibid.p16
[30]Ibid.p73
[31]Criminal code (2009),Article217-230

តាមផ្លូវច្បាប់យ៉ាងតឹងរឹងនៃអំពើហិង្សាក្នុងគ្រួសារ និងផ្តល់ឲ្យមានកិច្ចអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន និងដោយអនុញ្ញាតិឲ្យតុលាការចេញបទបញ្ជាការពារជនរងគ្រោះទាំងនោះ[32]។

**ឃ. មធ្យោបាយដោះស្រាយបែបរដ្ឋបាលនៅប្រទេសកម្ពុជា:** ជនរងគ្រោះអាចសុំជំនួយពីអាជ្ញាធរមូលដ្ឋាន ដូចជាអាជ្ញាធរស្រុកឬក្រុមប្រឹក្សាឃុំ។ មេឃុំទទួលខុសត្រូវសន្តិសុខនៅក្នុងឃុំរបស់ខ្លួន។ ទោះជាយ៉ាងណា មានទិន្នន័យជាច្រើនបង្ហាញថាបញ្ញត្តិទាំងឡាយត្រូវបានបកស្រាយមិនស៊ីសង្វាក់គ្នា ហើយបង្ហាញទៀតផងថាអាជ្ញាធរមូលដ្ឋានព្យាយាមសម្រុះសម្រួលគូស្វាមីជាជាងធ្វើអន្តរាគមន៍ដើម្បីការពារជនរងគ្រោះ[33]។

**ង. កិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ:** កម្ពុជាគឺជាហត្ថលេខីនៅក្នុង សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស(១៩៤៨) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នការរើសអើងប្រឆាំងនឹងស្ត្រី(១៩៧៩) អនុសញ្ញាស្តីពីសិទ្ធិកុមារ(១៩៨៩) និងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីអំពីការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី(១៩៩៣)។

## ៦. តើប្រទេសកម្ពុជាបច្ចុប្បន្ន មានគោលនយោបាយអ្វីខ្លះ ដើម្បីឆ្លើយតបការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ?

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលនយោបាយសំខាន់ៗជាច្រើនផ្តោតលើសារៈសំខាន់ស្ត្រីជាទូទៅ និងជាពិសេសអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ។ គោលនយោបាយជាក់លាក់ទាំងឡាយដែលទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារមានដូចខាងក្រោម៖

**ក. ផែនការនារីរតនៈទី៣ (២០០៩-២០១៣) :** ផែនការយុទ្ធសាស្ត្រប្រាំឆ្នាំលើកទីបីរបស់ក្រសួងកិច្ចការនារី បញ្ជាក់យ៉ាងច្បាស់ អំពីអំពើហិង្សាក្នុងគ្រួសារ ហើយនិងបានគូសបញ្ជាក់អំពីតម្រូវការបន្ថែមលើផ្នែកច្បាប់ និងគោលនយោបាយក្នុងការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ។ ផែនការនារីរតនៈទី៣នេះគឺជាយន្តការជាតិមួយសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ និងលើកកំពស់សមភាពយេនឌ័រ[34] ។

**ខ. ផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៣):** ផែនការនេះបានទទួលស្គាល់អំពើហិង្សាក្នុងគ្រួសារថាជាបញ្ហាប្រឈមរ៉ាំរ៉ៃនិងមានគោលដៅដោះស្រាយបញ្ហានេះតាមរយៈការពង្រឹងច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងតាមរយៈការបង្កើតច្បាប់ប្រឆាំងការ

[32]Law on the Prevention of Domestic Violence and the Protection of Victims, Article 3
[33] “Violence against women”,A baseline survey, Final Report Cambodia 2005,p13
[34] Ministry of women’s affairs,“Five year strategy plan 2009-2013:NearyRattanakIII”.”, November 2009,p.2

ជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទព្រមទាំងបង្កើតផែនការសកម្មភាពជាតិលើកដំបូងស្តីអំពីការបង្ការអំពើហិង្សាលើស្ត្រី[35]។

**គ. គោលដៅអភិវឌ្ឍន៍សហសវត្សរ៍** : រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាកាត់បន្ថយរាល់ទម្រង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី និងកុមារ ហើយគោលដៅទាំងនេះ បូកបញ្ចូលទាំងសកម្មភាពជាក់លាក់ រួមមានកំណែទម្រង់ច្បាប់ និងការស្រាវជ្រាវដើម្បីបង្ការ និងកម្មវិធីផ្តល់ប្រឹក្សា។[36]

## ៧. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការកាត់បន្ថយរាល់ទម្រង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី និងកុមារជាអត្ថិភាព និងបានអនុម័តច្បាប់មួយចំនួនដូចជា ផ្តល់សច្ចាប័នដល់សន្ធិសញ្ញាអន្តរជាតិ និងបង្កើតគោលនយោបាយទាំងឡាយដើម្បីឈានទៅដល់ការបញ្ចប់បញ្ហានេះ។ ទោះជាយ៉ាងណា ខណៈដែលបញ្ហាក្នុងការអនុវត្តន៍គោលនយោបាយទាំងនេះនៅមានបន្តជាបញ្ហាចម្បងនៃអំពើហិង្សាក្នុងគ្រួសារ វិសមភាពនិងភាពងាយរងគ្រោះរបស់ស្ត្រី តម្រូវឲ្យមានការប្តេជ្ញារយៈពេលវែងដើម្បីដោះស្រាយបញ្ហាទាំងនេះ។

[35] The Royal government of Cambodia,"Rectanglar Strategy Phase III , 2013.p40
[36] Ministry of women's affairs, "Violence against women",A baseline survey, Final Report Cambodia 2005,p15

# គន្ថនិទេស

Cambodia daily. Com, “Report Finds Poor Implementation of Domestic Violence Law”. January 21,2014.
http://www.cambodiadaily.com/archives/report-finds-poor-implementation-of-domestic-violence-law-50906/

Fulu, E., Warner, X. Miedema, S. Jewkes, R. Roselli, T. and Land, J. (2013).*Why Do Some Men Use Violence Against Women and How Can We Prevent It? Quantitative Findings from the United Nations Multi-Country Study on Men and Violence in Asia and the Pacific*. Bangkok: UNDP, UNFPA, UN Women and UNV.

LICADHO,” Violence against women in Cambodia 2006”, *Report 2007*,p1

Ministry of Justice (Criminal code of Kingdom of Cambodia,2009).

Ministry of Women's Affairs, “The Violence Against Women 2009 Follow Up Survey”,p.33-79

Ministry of women’s affairs, “Violence against women”, A baseline survey, Final Report Cambodia 2005,p13-36

Ministry of women’s affairs, “Five year strategy plan 2009-2013: Neary Rattanak III”, November 2009,p2

Peace Resources, “Understanding Family Violence in Cambodia” , Accessed on March 14,2014
http://pbresources.blogspot.com/2009/06/part-1-basic-understandings-of-violence.html

Royal Kram (Law on the Prevention of Domestic Violence and the Protection of Victims, 2005).

The Royal government of Cambodia, “Rectangular Strategy Phase III, 2013”, p. 40.

UNDP Cambodia and VBNK in collaboration with the Ministry of Justice and the Ministry of Interior, 2010“Talking about domestic violence in Cambodia”,p10,21,27,73

Women and children in Cambodia are particularly vulnerable to violence and abuse, accessed on March 14, 2014. http://wopema.org/index.php?id=20